# សុន្ទរកថា និងរបាយការណ៍
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ ២០១៨
# និងទិសដៅការងារឆ្នាំ ២០១៩
# របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ថ្ងៃទី៥ ដល់ ៧ ខែមីនា ឆ្នាំ២០១៩

---------------------------

- សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរព លោកជំទាវ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា តំណាងក្រសួង-ស្ថាប័ន
- ភ្ញៀវកិត្តិយស អង្គសន្និបាតទាំងមូល ជាទីមេត្រី!

ជាបឋម ខ្ញុំបាទសូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នាព្រឹកនេះ។ វត្តមានដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** បង្ហាញអំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ **សម្តេច**

ចំពោះការងារការបរទេស និងចំពោះមន្ត្រីការទូត មន្ត្រីរាជការ និងបុគ្គលិកក្រសួងការបរទេសទាំងមូល។

ខ្ញុំបាទក៏សូមអរគុណផងដែរចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងតំណាងក្រសួង-ស្ថាប័ននានា ។

ក្រសួងបានបញ្ចប់នូវការប្រជុំរយៈពេល២ថ្ងៃ ដោយមានការចូលរួមពីប្រធានស្ថានតំណាងរបស់កម្ពុជានៅបរទេស ដែលមានជាអាទិ៍ ឯកអគ្គរាជទូតចំនួន២៨ តំណាងអចិន្ត្រៃយ៍ចំនួន៤ អគ្គកុងស៊ុលចំនួន១១ និងកុងស៊ុលកិត្តិយសចំនួន៦។ សន្និបាតបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលក្រសួងសម្រេចបានក្នុងការងារធំៗទាំង ៥ ដែលខ្ញុំបាទសូមគោរពរាយការណ៍ដោយសង្ខេបដូចតទៅ៖

## ការងារធំទី ១៖ ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ និងអធិបតេយ្យភាព

ឆ្នាំ២០១៨ គឺជាឆ្នាំដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើការតស៊ូយ៉ាងស្វិតស្វាញ នៅលើសមរភូមិការទូត និងសាធារណៈមតិ ដើម្បីការពារ និងលើកកម្ពស់មុខមាត់ និងកិត្យានុភាពជាតិ នៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ ក៏ដូចជាការទប់ទល់វាយបកប្រឆាំងទៅនឹងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។

- ក្រសួងបានចងក្រង និងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវអត្ថបទ«ប្រាប់ពីការពិត» បកស្រាយពីសភាពការណ៍

នយោបាយនៅកម្ពុជា និងចេញសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់ ឆ្លើយតបចំពោះការបំផ្លើស មួលបង្កាច់ខុសពីសភាពការណ៍ពិត និងបញ្ជាក់ពីជំហរម៉ឺងម៉ាត់ដាច់ខាតក្នុងការការពារឯករាជ្យ អធិបតេយ្យជាតិកម្ពុជា។

- ចាត់បញ្ជូនបេសកកម្មសុឆន្ទៈទៅបកស្រាយបំភ្លឺជូនឥស្សរជនសំខាន់ៗនៃគណៈកម្មការអឺរ៉ុប និងជួបពិភាក្សាជាមួយសមាជិកសភាអឺរ៉ុបមួយចំនួន។
- ធ្វើការចរចាជាមួយប្រទេសជិតខាងនៅក្នុងការដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ដោយសន្តិវិធី ដើម្បីប្រែក្លាយតំបន់ព្រំដែនឲ្យទៅជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។
- ជួយអន្តរាគមន៍សង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ប្រជាពលរដ្ឋខ្មែរ ជាពិសេស ពលករពលការីនីខ្មែរដែលរងគ្រោះពីការរំលោភបំពាននៅបរទេសបានចំនួន ៨៤៨៩នាក់។

## ការងារធំទី ២៖ ការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន រៀងវៃ តបទៅនឹងសំពាធភូមិសាស្ត្រនយោបាយ

បច្ចុប្បន្ន កម្ពុជាមានទំនាក់ទំនងការទូតជាមួយប្រទេសជាមិត្តចំនួន ១៧២។ គិតត្រឹមឆ្នាំ២០១៨នេះ កម្ពុជាបានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការជាមួយ ៣៤ប្រទេស។

កម្ពុជាបានរឹតចំណងមិត្តភាព និងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសជាច្រើននៅទ្វីបអាស៊ី អាមេរិក អាហ្វ្រិក មជ្ឈិមបូព៌ា និងនៅអឺរ៉ុប។ យើងក៏កំពុងរៀបចំបើកដំណើរការស្ថានទូតពាបន្ថែមទៀតនៅប្រទេសប៊ុលហ្គារី តួកគី និងស៊ែរប៊ី សំដៅបង្កើនទំនាក់ទំនង និងពង្រឹងទំនុកចិត្តផ្នែកនយោបាយ សេដ្ឋកិច្ច និងបើកច្រកទីផ្សារថ្មី។

យើងបានរៀបចំ និងសហការរៀបចំ ព្រះរាជទស្សនកិច្ចរបស់ **ព្រះករុណាព្រះមហាក្សត្រ** នៅចិន និងវៀតណាម និងទស្សនកិច្ចផ្លូវការ និងការងារជាបន្តបន្ទាប់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅឥណ្ឌា អូស្ត្រាលី ចិន សឹង្ហបូរី វៀតណាម ជប៉ុន ឡាវ នេប៉ាល់ តួកគី និងស្ថាប័នអង្គការសហប្រជាជាតិនៅញូវយ៉ក និងហ្សឺណែវ។

ទន្ទឹមនឹងនេះ កម្ពុជាក៏បានរៀបចំទទួលបដិសណ្ឋារកិច្ចទស្សនកិច្ចផ្លូវការរបស់នាយករដ្ឋមន្ត្រីចិន អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ត និងប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងទទួលប្រធានរដ្ឋ និងនាយករដ្ឋមន្ត្រីនៃបណ្តាប្រទេសទន្លេមេគង្គ ក្នុង ឋានៈជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ និងកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី៣។

ក្រៅពីនេះ កម្ពុជាក៏បានចូលរួមក្នុងវេទិកាជាន់ខ្ពស់កម្រិតតំបន់ អនុតំបន់ និងអន្តរជាតិជាច្រើនដូចជា កិច្ចប្រជុំកំពូលអាស៊ី–អឺរ៉ុប

កិច្ចប្រជុំកំពូល ACMECS, កិច្ចប្រជុំកំពូលមហាអនុតំបន់ទន្លេមេគង្គ (GMS), កិច្ចប្រជុំកំពូលស្តីពីតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា ឡាវ និងវៀតណាម, កិច្ចប្រជុំកំពូលមេគង្គ-ជប៉ុន, កិច្ចប្រជុំកំពូលអាស៊ី-ប៉ាស៊ីហ្វិក, សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍនៃវេទិកាវិនិយោគពិភពលោក, កិច្ចប្រជុំកំពូលអង្គការកិច្ចសហប្រតិបត្តិការសៀងហៃ និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ជាដើម។

ក្នុងកម្រិតរដ្ឋមន្ត្រីការបរទេស ខ្ញុំបាទផ្ទាល់បានបំពេញទស្សនកិច្ចផ្លូវការ និងការងារជាបន្តបន្ទាប់នៅមីយ៉ាន់ម៉ា ឡាវ ឥណ្ឌូនេស៊ី សិង្ហបូរី ជប៉ុន ហុងគ្រី រូម៉ានី តួកគី វៀតណាម និងបែលហ្ស៊ិក និងបានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម, កម្ពុជា-ឡាវ,កម្ពុជា-ឥណ្ឌូណេស៊ី, កម្ពុជា-មីយ៉ាន់ម៉ា និងកិច្ចប្រជុំគណៈកម្មាធិការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី។

ក្នុងយន្តការពហុភាគី កម្ពុជាបានជាប់ឆ្នោតជាអនុប្រធាននៃសម័យប្រជុំលើកទី៧៣របស់មហាសន្និបាតអ.ស.ប. ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០១៩ និងជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម (ECOSOC) របស់អ.ស.ប. សម្រាប់អាណត្តិឆ្នាំ២០១៩ និងបានទទួលកិត្តិយសធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ១៣ នៅឆ្នាំ២០២០។

**ការងារធំទី ៣៖ អនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ ដើម្បីពង្រឹងសេដ្ឋកិច្ចជាតិ**

នេះគឺជាការចាប់ផ្តើមផ្តោតសារៈសំខាន់ក្នុងការរួមចំណែកជំរុញ និងលើកស្ទួយទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ និងទេសចរណ៍ បន្ថែមពីលើការងារការទូតប្រពៃណីធម្មតា។

**ការងារធំទី ៤៖ គឺការចូលរួមអោយកាន់តែសកម្មថែមទៀតដល់បុព្វហេតុ សន្តិភាព ស្ថិរភាព និងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក តួយ៉ាងប្រយុទ្ធប្រឆាំងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការប្រែប្រួលអាកាសធាតុ ជំងឺឆ្លង។ល។**

ក្នុងការចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អ.ស.ប. ចាប់តាំងពីឆ្នាំ ២០០៦ ដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងប្រមាណ ៦០០០នាក់ (ស្ត្រីចំនួន ២៩០នាក់) ឲ្យទៅបំពេញការងារនៅក្នុងប្រទេសចំនួន ៨។

កម្ពុជាក៏បានចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សា និងការអនុម័តសេចក្តីសម្រេចរបស់សម័យប្រជុំមហាសន្និបាត អ.ស.ប. លើកទី ៧៣ ដែលមានសរុបចំនួន ២៨៤ ពាក់ព័ន្ធនឹងវិស័យសន្តិភាព សន្តិសុខ ការអភិវឌ្ឍ សិទ្ធិមនុស្ស និងបញ្ហាថវិកា។ល។

**ការងារធំទី ៥៖ ការបន្តការដ្ឋានកំណែទំរង់ស្ថាប័ននៅក្នុងក្រសួងដើម្បីរៀបចំអង្គអ្នកការទូតប្រកបដោយវិជ្ជាជីវៈ ស្នេហាជាតិ សកម្ម និងមានសមត្ថភាព**

កំណែទម្រង់របស់ក្រសួងគឺមានទិសដៅធ្វើឲ្យប្រសើរឡើងនូវ លក្ខខណ្ឌ ប្រសិទ្ធភាពការងារ និងបង្កើតបរិយាកាសសមធម៌។ ក្នុងការងារកំណែទម្រង់នេះ យើងបានដាក់សម្ពោធប្រើប្រាស់ជាផ្លូវការនូវវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ និងអគារបន្ថែមថ្មីសម្រាប់មន្ត្រីបំពេញការងារ, ធ្វើសមាហរណកម្មក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ (កសវព) ចូលក្នុងក្របខ័ណ្ឌក្រសួង, រៀបចំការធ្វើឌីជីថលូបនីយកម្មក្នុងទីស្តីការក្រសួង និងធ្វើឲ្យប្រសើរឡើងនូវការផ្សព្វផ្សាយព័ត៌មានតាមគេហទំព័រ និងបណ្តាញសង្គមរបស់ក្រសួង, និងបានពង្រឹងសមត្ថភាព និងកសាងជួរមន្ត្រីការទូត ប្រកបដោយវិជ្ជាជីវៈ សីលធម៌ គុណធម៌ វិន័យ និងធន្ទះខ្ពស់។

## សម្តេចតេជោនាយករដ្ឋមន្ត្រី
## ឯកឧត្តម លោកជំទាវ លោក លោកស្រី

សន្និបាតឆ្នាំនេះ ក៏មានរៀបចំកិច្ចប្រជុំចង្អៀតដែលមានការពិភាក្សាជាក្រុម ដើម្បីផ្តល់លទ្ធភាពឲ្យមានការផ្លាស់ប្តូរមតិយោបល់ត្រង់ទៅត្រង់មក និងស៊ីជម្រៅជាងឆ្នាំមុនៗ ទាំងលើផ្នែកខ្លឹមសារការងារ និងទិសដៅយុទ្ធសាស្ត្រ។

អង្គសន្និបាតបានពិភាក្សា និងធ្វើការវាយតម្លៃថា ឆ្នាំ ២០១៩ និងបណ្តាឆ្នាំតទៅមុខ ស្ថានការណ៍ពិភពលោកនឹងបន្តប្រែប្រួលយ៉ាងជ្រាលជ្រៅ ស្មុគស្មាញ ឆាប់រហ័ស និងពិបាកប៉ាន់ស្មានបាន។

ដំណើរប្រែប្រួលទៅកាន់ប្រព័ន្ធពហុប៉ូលនៅបន្តទៅមុខ។ ការងើបឡើងកាន់តែជាក់ច្បាស់របស់តួអង្គថ្មីៗនៅលើឆាកអន្តរជាតិ នឹងទាញការទទួលខុសត្រូវក្នុងការចាត់ចែងកិច្ចការពិភពលោកទៅរកប៉ូលថ្មី បង្កើតជាការប្រកួតប្រជែងជាយុទ្ធសាស្ត្រ ដើម្បីអំណាច ឥទ្ធិពល និងផលប្រយោជន៍។

ការងាកចេញរបស់មហាអំណាចទី ១ ពីប្រព័ន្ធពហុភាគីនិយម ទៅកាន់ឯកតោភាគីនិយម និងគាំពារនិយម កំពុងគំរាមដល់ប្រព័ន្ធសណ្តាប់ធ្នាប់ពិភពលោកបច្ចុប្បន្ន ដែលជាវិធានសម្រាប់ចាត់ចែងទំនាក់ទំនងអន្តរជាតិ អស់កាលជាង៧០ឆ្នាំមកហើយ។

ភ្នក់ជម្លោះតាមតំបន់នានានៅមជ្ឈិមបូព៌ា អឺរ៉ុបខាងកើត អាហ្វ្រិក អាមេរិកឡាទីន និងនៅអាស៊ី បញ្ហាប្រឈមធ្ងន់ធ្ងរ តួយ៉ាង អំពើភេរវកម្ម វិបត្តិជនភៀសខ្លួន ឧក្រិដ្ឋកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យា ឧក្រិដ្ឋកម្មឆ្លងដែន ការជួញដូរមនុស្ស / គ្រឿងញៀន ការប្រែប្រួលធាតុអាកាស និងបញ្ហាបរិស្ថាន ជំងឺឆ្លង និងគ្រោះធម្មជាតិ។ល។ នឹងនៅតែបន្តគំរាមកំហែងដល់សន្តិសុខពិភពលោក និងត្រូវការការរួមកម្លាំងទាំងអស់គ្នាដើម្បីឆ្លើយតបដោះស្រាយ។

តំបន់អាស៊ី-ប៉ាស៊ីហ្វិក នឹងនៅតែជាចំណុចកណ្តាលនៃការប្រកួតប្រជែងរបស់មហាអំណាចធំៗ។ ការងើបឡើងរបស់បណ្តាប្រទេសនៅអាស៊ី នាំមុខដោយ ចិន ជប៉ុន ឥណ្ឌា កូរ៉េខាងត្បូង និង

អាស៊ាន កំពុងធ្វើឲ្យជញ្ជីងអំណាចផ្អៀងពីភាគខាងលិច មកភាគខាងកើត។

អាស៊ាននឹងបន្តជាគម្រូនៃសមាហរណកម្មប្រកបដោយជោគជ័យផង ជាកម្មវត្ថុនៃការចង់ភ្ជាប់ភាពជាដៃគូជាមួយផង និងក៏ជាកន្លែងដែលទទួលរងឥទ្ធិពល និងសម្ពាធពីការប្រកួតប្រជែងនោះផង។

កម្ពុជាយើង ក៏ដូចជាប្រទេសតូចធំនានា ក្នុងតំបន់ និងពិភពលោក នឹងបន្តទទួលរងផលប៉ះពាល់ពីឥទ្ធិពល និងសម្ពាធ ដែលកើតចេញពីការប្រកួតប្រជែងកាន់តែតានតឹងឡើងរបស់មហាអំណាចធំៗ។

អង្គសន្និបាតបានផ្តល់មតិយោបល់ជាច្រើនពាក់ព័ន្ធនឹងការដោះស្រាយការប្រឈមនានាដែលថ្នាក់ដឹកនាំ មន្ត្រីការទូតយើងជួបប្រទះក្នុងការការពារឯករាជ្យ អធិបតេយ្យភាព ការពារយុត្តិធម៌ជូនរាជរដ្ឋាភិបាលកម្ពុជា កែតម្រូវទស្សនៈពីខាងក្រៅដែលចាត់ទុកថាកម្ពុជាមានការដើរថយក្រោយផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ការពារសិទ្ធិអធិបតេយ្យរបស់យើងក្នុងការអនុវត្តន៍នីតិរដ្ឋនៅប្រទេសយើង។

អង្គសន្និបាតបានផ្លាស់ប្តូរមេរៀន បទពិសោធន៍ជាច្រើនក្នុងការងារការទូតទ្វេភាគី និងពហុភាគីក្នុងវិស័យនយោបាយ សេដ្ឋកិច្ច–សង្គម សិទ្ធិមនុស្ស ការងារទំនាក់ទំនងសាធារណៈ ការឡូប៊ីជាមួយអ្នកនយោបាយ សមាជិកសភា ធុរជន ។ល។

អង្គសន្និបាតបានពិភាក្សាអំពីការជំរុញសកម្មភាពនានាដើម្បីបង្កើនមិត្តនៅខាងក្រៅ រក្សាមិត្តប្រពៃណី ទោះបីជាសម្ព័ន្ធមិត្តរបស់អាមេរិកក៏ដោយ និងកសាងមិត្តថ្មី ឬស្តារឡើងវិញទំនាក់ទំនងល្អជាមួយមិត្តចាស់។

ក្រៅពីការពិភាក្សាខាងលើ យើងក៏បានស្តាប់បទឧទ្ទេសនាមលើប្រធានបទសំខាន់ៗដូចជា «យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា», «វិធានការនានាដើម្បីទប់ទល់នឹងយថាភាពនៃការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធ-គ្រប់មុខទំនិញទាំងអស់លើកលែងសព្វាវុធ», «ជំហររបស់កម្ពុជាចំពោះបញ្ហាការប្រែប្រួលអាកាសធាតុ» និង «ការជំរុញការទូតសេដ្ឋកិច្ច ទេសចរណ៍ និងវប្បធម៌» ផងដែរ។

## សម្តេចតេជោនាយករដ្ឋមន្ត្រី
## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងបានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង និងបានដឹកនាំវិស័យការទូតប្រកបដោយសុភវិនិច្ឆ័យ និងគតិបណ្ឌិត សម្រាប់កម្ពុជាមួយឯករាជ្យ អធិបតេយ្យ សន្តិភាព សុខដុម អភិវឌ្ឍន៍ និងប្រកបដោយសេចក្តីថ្លៃថ្នូរ។

ខ្ញុំក៏សូមអរគុណបណ្តាក្រសួង ស្ថាប័ន ស្ថានទូត ស្ថានបេសកកម្ម អង្គការអន្តរជាតិនានាដែលតែងផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់បេសកកម្មរបស់ក្រសួង។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ទទួលបាននូវពុទ្ធពរទាំងប្រាំប្រការ និងទទួលបាននូវជ័យជំនះគ្រប់ភារកិច្ច។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាមានប្រសាសន៍ សំណេះសំណាល និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់។ សូមគោរពអញ្ជើញ **សម្តេច** ។

---------------------------